ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្ដីប្រកាសព័ត៌មាន
## រដ្ឋមន្ត្រីការបរទេសប៉ាគីស្ថានអបអរសាទរកម្ពុជាសម្រាប់ភាពជោគជ័យ ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី ៥៥ និង កិច្ចប្រជុំពាក់ព័ន្ធ

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បាន ជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម Bilawal Bhutto Zardari រដ្ឋមន្ត្រីការបរទេសនៃ សាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០២២ នៅក្នុងឱកាសនៃកិច្ចប្រជុំវេទិកា តំបន់អាស៊ានលើកទី២៩ រៀបចំដោយកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រី Bilawal Bhutto Zardari បានអបអរសាទរកម្ពុជាចំពោះភាពជោគជ័យក្នុងការធ្វើ ជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ។ ឯកឧត្តម រដ្ឋមន្ត្រីការបរទេសទាំងពីរបានកត់សម្គាល់ដោយក្ដីរីករាយចំពោះទំនាក់ទំនងជាមិត្តភាព និងកិច្ច សហប្រតិបត្តិការល្អដែលមានស្រាប់រវាងប្រទេសទាំងពីរ។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្ដេជ្ញា ចិត្តរួមគ្នាក្នុងការធ្វើការយ៉ាងជិតស្និទ្ធបន្ថែមទៀតដើម្បីលើកកម្ពស់ទំនាក់ទំនងទ្វេភាគី ជាពិសេស លើវិស័យនយោបាយ និងសេដ្ឋកិច្ច ខណៈដែលប្រទេសទាំងពីរនឹងប្រារព្ធខួបលើកទី៧០ នៃ ទំនាក់ទំនងការទូតនៅឆ្នាំនេះ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងរដ្ឋមន្ត្រីការបរទេស Bilawal Bhutto Zardari បាន គូសបញ្ជាក់អំពីសារៈសំខាន់នៃការផ្លាស់ប្ដូរទស្សនកិច្ចកម្រិតខ្ពស់។ ក្នុងគោលដៅនេះ ឯកឧត្តមរដ្ឋមន្ត្រី Bilawal Bhutto Zardari បានអញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទៅបំពេញទស្សនកិច្ច នៅប៉ាគីស្ថាន ក្នុងពេលវេលាមួយសមស្រប។

ក្រសួងការបរទេសនៃប្រទសទាំងពីរ បានឯកភាពជំរុញឱ្យមានការចុះហត្ថលេខាលើអនុស្សរណៈនៃ ការយោគយល់គ្នា ស្ដីពីកិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងក្រសួងការបរទេស ទាំងពីរ ឱ្យបានឆាប់តាមដែលអាចធ្វើបាន ដើម្បីជាចំណុចចាប់ផ្ដើមសម្រាប់ការពង្រឹងកិច្ចសហ ប្រតិបត្តិការទ្វេភាគី ជាពិសេសការជំរុញពាណិជ្ជកម្ម ការបង្កើតទំនាក់ទំនងរវាងសហគមន៍ធុរកិច្ចនៃ ប្រទេសទាំងពីរ និងការផ្សារភ្ជាប់រវាងប្រជាជននិងប្រជាជន៕

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២២

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ជុំ សុន្ទរី**

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh